# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 1229

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : បង្កើនការគ្រប់គ្រងចម្ការឈើម៉ៃសាក់ សម្រាប់ប្រទេសក្នុងមហាអនុតំបន់មេគង្គ

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/03/19

កាលបរិច្ឆេទបញ្ចប់គម្រោង 30/03/21

៣. ចំណាយគម្រោងសរុប $49,500

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT Forestry Administration

អង្គភាពទទួលខុសត្រូវ រដ្ឋបាលព្រៃឈើ

៥. ស្ថានភាពគម្រោង គម្រោងដែលបានបញ្ចប់

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹង និងការកែទម្រង់ស្ថាប័ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

- ការបណ្តុះបណ្តាលបច្ចេកទេសរុក្ខវប្បកម្ម សម្រាប់ការអភិវឌ្ឍចម្ការឈើដាំម៉ៃសាក់
- ជំរុញកំណើនលូតលាស់ឈើសម្រាប់លើកកម្ពស់ការអភិវឌ្ឍចម្ការឈើ និងផលិតកម្មឈើមានប្រភពពីចម្ការម៉ៃសាក់ឱ្យមានប្រសិទ្ធិភាពសម្រាប់ការផ្គត់ផ្គង់ឈើសំណង់
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន និងវិស័យឯកជនក្នុងការដាំស្តារព្រៃឈើឡើងវិញ
- ការបង្កើនគម្របព្រៃឈើតាមរយៈស្តារព្រៃឈើឡើងវិញ

១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពង់ស្ពឺ, កំពង់ចាម,

១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

ដើម្បីបង្កើតឱ្យមានខ្សែសង្វាក់ផ្គត់ផ្គង់ស្របច្បាប់ និងមាននិរន្តភាពនៃប្រភេទឈើម៉ៃសាក់ ដោយមានការចូលរួមពីសហគមន៍មូលដ្ឋាន ចម្ការឈើដាំឯកជនខ្នាតតូច និងរដ្ឋនៃបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ។

១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

គម្រោងបង្កើនការគ្រប់គ្រងចម្ការឈើម៉ៃសាក់ សម្រាប់ប្រទេសក្នុងមហាអនុតំបន់មេគង្គ បានចុះអនុស្សរណៈ
នៃការយោគយល់គ្នារវាងអង្គការ ITTO ប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩
គម្រោងនេះជាប្រភេទថ្នាក់តំបន់សហការអនុវត្តរួមគ្នា
ដែលមានការិយាល័យអនុវត្តគម្រោងថ្នាក់តំបន់ស្ថិតនៅនាយកដ្ឋានភូមិន្ទព្រៃឈើប្រទេសថៃ រដ្ឋបាលព្រៃឈើនៃប្រទេសកម្ពុជា ឡាវ វៀតណាម និងសហភាពមីយ៉ាន់ម៉ា ។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

គម្រោងនេះគឺដើម្បីលើកកម្ពស់ សម្របសម្រួលការគ្រប់គ្រង
ការអភិវឌ្ឍប្រកបដោយនិរន្តភាពនូវធនធានឈើម៉ៃសាក់សម្រាប់ផលប្រយោជន៍រួមគ្នា
និងសុខុមាលភាពរបស់ប្រទេសក្នុងអនុតំបន់មេគង្គ។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនេះបានបណ្តុះបណ្តាលមន្ត្រីរដ្ឋបាលព្រៃឈើជាង និងវិស័យឯកជន ដែលរួមមានបុគ្គលិកក្រុមហ៊ុនឯកជននៅខេត្តកំពង់ស្ពឺ និងម្ចាស់ចម្ការឈើម៉ៃសាក់ ពិសេសនៅខេត្តកំពង់ចាម ព្រមទាំងសហគមន៍មូលដ្ឋានជាង ៥០រូប
ដើម្បីទទួលបានជំនាញបច្ចេកទេសបង្កាត់ពូជឈើម៉ៃសាក់ (បច្ចេកទេសផ្សាំ) ការធ្វើសុរុង្គឡុកម្ម និងហាលនៅក្នុងចម្ការឈើម៉ៃសាក់
ដើម្បីបង្កើតប្រសិទ្ធិភាពការលូតលាស់ឈើ ការបង្កើតមុខការងារបដល់កម្មករ និងសហគមន៍មូលដ្ឋាន
ដែលនៅក្បែរចម្ការឈើដាំម៉ៃសាក់ឯកជន ឬក្រុមហ៊ុនដែលដាំឈើម៉ៃសាក់។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | គ្មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | មិនទានចាប់ផ្តើម |

១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

គម្រោងនេះមិនមានផលប៉ះពាល់ជាអវិជ្ជមានដល់ប្រជាជន និងបរិស្ថានទេ។ ផ្ទុយមកវិញគម្រោងនេះ
ផ្តល់អត្ថប្រយោជន៍ជាច្រើនវិស័យឯកជន និងសហគមន៍មូលដ្ឋានតាមរយៈការផ្តល់បច្ចេកទេសដាំឈើម៉ៃសាក់ឱ្យឆាប់ទទួលបានផល
និងមានប្រសិទ្ធភាពខ្ពស់ខាងផ្នែកសេដ្ឋកិច្ច ជាមួយនិងការពិសោធន៍សិក្សាស្រាវជ្រាវ ដែលនឹងជួយដល់ការបង្កើនគម្រប
បៃតងយ៉ាងឆាប់រហ័ស។ គម្រោងនេះ នឹងរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ
តាមរយៈការបង្កើតការងារពីការអនុវត្តបច្ចេកទេសរុក្ខវប្បម្ម ដែលជួយលើកកម្ពស់ជីវភាពរបស់សហគមន៍
និងផលចំណេញដល់វិស័យឯកជនបានយ៉ាងឆាប់រហ័ស។

១៩. ការប្រែប្រួល អាកាសធាតុ

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **២. ព្រៃឈើ** | 70 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្រ្តីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្រ្តីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនេះមិនមានផលប៉ះពាល់ដល់តួនាទីរបស់បុរស និងស្ត្រីក្នុងទីតាំងរបស់គម្រោងឡើយ ព្រោះសមាសភាពស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងតួនាទីជាមន្ត្រីគម្រោង និងសកម្មភាពនានារបស់គម្រោង។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**មន្ត្រីអនុវត្តគម្រោងមានជំនាញ សមត្ថភាព និងបទពិសោធន៍គ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង។**

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

**គម្រោងបានសម្រេចនូវលទ្ធផលដូចខាងក្រោម៖**

**• បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសរុក្ខវប្បកម្មសម្រាប់កាត់ផ្សាំកូនម៉ៃសាក់ ការជ្រើសរើសពូជ និងការថែទាំចម្ការឈើម៉ៃសាក់ ដើម្បីទទួលបានកំណើនលូតលាស់លឿន**

**• បានបង្កើតឡូតិ៍គម្រូពិសោធន៍ចម្ការឈើម៉ៃសាក់ដែលធ្វើការក្រៃមែក និងមិនធ្វើការក្រៃមែក ដោយបានវាស់វែងកំណើនលូតលាស់អង្កត់ផ្ចិតនិងកម្ពស់ចំនួន ៣លើក**

**• បានរៀបចំសម្ភារៈសម្រាប់បណ្តុះបណ្តាល និងផ្សព្វផ្សាយស្តីពីបច្ចេកទេសរុក្ខវប្បកម្មសម្រាប់កាត់ផ្សាំកូនម៉ៃសាក់ ការជ្រើសរើសពូជ និងការថែទាំចម្ការឈើម៉ៃសាក់ សម្រាប់ផ្សព្វផ្សាយដល់សហគមន៍ និងវិស័យឯកជន**

**• បានរៀបចំទស្សនកិច្ចសិក្សា ដើម្បីផ្សព្វផ្សាយជាសាធារណៈការអនុវត្តដាំម៉ៃសាក់ជាចម្ការកសិ-រុក្ខកម្ម នៅចម្ការម៉ៃសាក់ក្នុងខេត្តកំពង់ចាម**

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 20.2 | 10.6 | 9.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 20.2 | 10.6 | 9.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារៈ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 20.2 | 10.6 | 9.1 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2020 | | 2021 | 2022 | 2023 | 2024 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2022-2024 | |
| | | | | | | | | |
| ចំណូលពីគម្រោង | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ថវិកាជាតិ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ | 20.2 | 10.6 | 9.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Japan | 20.2 | 10.6 | 9.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់ | 20.2 | 10.6 | 9.1 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: